# រឿងខ្មោចយក្ខនិងកូនក្មេងតូច

( ចាក ម. វា. )

( អានិសង្សនៃការរលឹកនូវពុទ្ធគុណ )

ក្នុង ពុទ្ធសម័យ មានបុរសសម្មាទិដ្ឋិម្នាក់រកស៊ីកាប់អុសលក់ ។ ថ្ងៃមួយបាននាំកូនតូចទៅកាប់អុសជាមួយផង ។ ដល់ពេលល្ងាចនាំកូននិងអុសមួយរទេះបរមកផ្ទះ ដល់ជិតនគរបានដោះគោលែងឱ្យស៊ីស្មៅ ហើយនាំកូនដេកលេងលើដីខ្ពស់ក្បែររទេះ ។ ឯគោក៏បានដើរចូលទៅនគរបាត់ ។

បុរសនោះដល់ពេលមកផ្ទះរកគោមិនឃើញ ក៏ឱ្យកូនចាំរទេះ រួចទៅរកគោនៅក្នុងនគរ ។ ពួកទ្វារបាលកាលបើដល់ពេលហើយក៏បិទទ្វារនគរ បុរសនោះមិនអាចចេញមកជួបកូនបានឡើយ ។

វេលាយប់នោះមានខ្មោចយក្ខពីររូប មួយសម្មាទិដ្ឋិ មួយមិច្ឆាទិដ្ឋិ ជាសំឡាញ់នឹងគ្នា នាំគ្នាទៅរកចំណីអាហារ ក៏បានឃើញកុមារតូចនោះដេកក្រោមរទេះ ។ ខ្មោចយក្ខមិច្ឆាទិដ្ឋិ និយាយថាអញចាប់កុមារនេះហើយ ខ្មោចយក្ខសម្មាទិដ្ឋិនិយាយឃាត់ថា កុំអ្នកមិនត្រូវធ្វើយ៉ាងនេះទេ ព្រោះកុមារនេះតែងរលឹកដល់គុណព្រះពុទ្ធថា នមោ ពុទ្ធស្ស ដូច្នេះរាល់ពេលពុំដាច់ ។ ខ្មោចយក្ខនោះមិនស្តាប់ក៏ស្ទុះទៅចាប់បំរុងនឹងបរិភោគ ។ កុមារនោះភ្ញាក់ឡើងភ្លាត់មាត់ថា នមោពុទ្ធស្ស ៗ ញាប់មាត់ដោយបុព្វចរិតដែលខ្លួនធ្លាប់សន្សំមកយូរហើយ ។ ខ្មោចយក្ខមិច្ឆាទិដ្ឋិ គ្រាន់តែឮនមោពុទ្ធស្ស ដូច្នោះ ក៏ភ័យតក់ស្លុតលែងកុមារនោះវិញ ហើយថយមកឈរក្នុងទីឆ្ងាយ ។

កាលនោះខ្មោចយក្ខសម្មាទិដ្ឋិនិយាយបំភ័យថា អំពើដែលអ្នកធ្វើនេះមានទោសធំណាស់ ហាក់ដូចជាប្រមាទមើលងាយព្រះពុទ្ធ ។ អ្នកឯងត្រូវទទួលទណ្ឌកម្មទើបរួចទោស គឺអ្នកឯងត្រូវទៅរកអាហារមកឱ្យកុមារនេះបរិភោគទើបបាន ។

ខ្មោចយក្ខព្រមធ្វើតាម ទើបនិយាយផ្តាំនឹងសំឡាញ់ថា ខ្ញុំទៅរកអាហារមិនទាន់ត្រលប់មកដរាបណា អ្នកត្រូវរង់ចាំខ្ញុំដរាបនោះ ផ្តាំហើយក៏ចាកចេញទៅរកអាហារនៅក្នុងនគរ ប្រទះឃើញភាជន៍មាសដ៏ធំមួយ ដែលពេញដោយអាហារមានរសជាតិឆ្ងាញ់ អាហារនេះជាព្រះស្ងោយព្រះបាទអជាតសត្រូវ ក៏យកទាំងភាជន៍មក

ឱ្យកុមារបរិភោគ មកជិតដល់បាននិម្មិតខ្លួនជាបិតារបស់កុមារនោះ យកអាហារមកឱ្យបរិភោគ ហើយសរសេរអក្សរភ្ជាប់នឹងភាជន៍មាសថា ពាក្យថាពុទ្ធំគឺកុមារកូនបុរសអ្នកលក់អុសបានពោលហើយ សេចក្ដីព្យាយាមនេះគឺខ្ញុំបានធ្វើឱ្យជាទណ្ឌកម្ម ហើយអធិដ្ឋានអក្សរនោះឱ្យព្រះរាជាទតកុំខាន រួចហើយយក្ខទាំងពីរបានបបួលគ្នាចៀសចេញពីទីនោះ ។

វេលាព្រឹកឡើងដល់ពេលព្រះមហាក្សត្រ នឹងសោយព្រះស្ងោយពួកព្រះរាជបំរើរកភាជន៍មិនឃើញឡើយ កោលាហលក៏កើតឡើងក្នុងព្រះរាជដំណាក់ ទើបព្រះមហាក្សត្រចាត់រាជបុរសឱ្យស្វែងរក រាជបុរសបានឃើញនៅក្នុងរទេះរបស់បុរសអ្នកលក់អុស ក៏ចាប់កុមារដែលនៅចាំរទេះយកទៅថ្វាយស្ដេច ។ ពេលនោះព្រះមហាក្សត្របានទតឃើញអក្សរដែលខ្មោចយក្ខសរសេរភ្ជាប់នឹង ភាជន៍មាសនេះហើយ ក៏មានព្រះទ័យសោមនស្សជ្រះថ្លាចំពោះកុមារនោះ បានព្រះរាជទានទីជាសេដ្ឋីដល់កុមារនោះ ។

សូមអស់លោកអ្នកអនុមោទនា !

(ចប់)